ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ :..៣២៧០...អ.រតន.

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៥

**ជម្រាបជូន**

**លោក លោកស្រីប្រធានរតនាគារខេត្ត**

**កម្មវត្ថុ ÷** ការកំណត់ឈ្មោះ និងលេខគណនីសម្រាប់កត់ត្រាចំណូលថវិការបស់ ក្រុង ស្រុក ដែលបានពីប្រភព SIDA។

**យោង ÷** យោងលិខិតលេខ ៥០០០ សហវ.អហក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការអនុញ្ញាតឱ្យរដ្ឋបាលក្រុង ស្រុក ប្រើប្រាស់ថវិកាដែលគាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអ៊ែត (SIDA)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោក លោកស្រីប្រធាន** ថា÷ យោងតាមលិខិតលេខ ៥០០០ សហវ.អហក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ បានអនុញ្ញាតឱ្យក្រុង ស្រុក ដែលបានទទួលថវិកាពី SIDA កន្លងមក ឱ្យធ្វើការកែសម្រួលគម្រោងថវិកាប្រចាំឆ្នាំ២០១៥ និងអនុវត្តការចំណាយទៅតាមនីតិវិធីហិរញ្ញវត្ថុរបស់ថវិកាក្រុង ស្រុក ដែលមានជាធរមាន។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរតនាគារជាតិ សូមបញ្ជាក់ឡើងវិញអំពីការប្រើប្រាស់គណនីសម្រាប់ការកត់ត្រាជាចំណូលថវិកានូវប្រភពបានពី SIDA ដូចតទៅ÷

- ក្រោយពេលទទួលបានគម្រោងចំណូល ចំណាយថវិកាពីប្រភព SIDA រតនាគារខេត្ត ត្រូវចាត់ចែងការកត់ត្រាទៅក្នុងគណនីចំណូលថវិកា “**ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ គណនីលេខ ៧៥១១**”។
- ចំពោះចំនួនទឹកប្រាក់សរុបនៃថវិកាបានពីប្រភព SIDA ត្រូវបានកត់ត្រានៅថ្នាក់កណ្តាលជាចំណូលថវិកាបានពីដៃគូអភិវឌ្ឍ និងជាចំណាយថវិកាផ្តល់ឧបត្ថម្ភធនដល់ក្រុង ស្រុក នៅឆ្នាំ២០១៣ រួចហើយ។

អាស្រ័យដូចបានជម្រាបខាងលើ សូម **លោក លោកស្រីប្រធាន** ចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ។

សូម **លោក លោកស្រីប្រធានរតនាគារខេត្ត** ទទួលនូវការរាប់អាន ពីខ្ញុំ

**អគ្គនាយក**

**អគ្គនាយកដ្ឋានរតនាគារជាតិ**

**បណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ**

**ចម្លងជូន÷**
- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
  “ ដើម្បីជ្រាប ”
- នាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានរតនាគារជាតិ
- រដ្ឋបាលក្រុង ស្រុក
  “ ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ